# សុន្ទរកថា
# សម្តេចវិបុលសេនាភក្តី សាយ ឈុំ
# ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងពិធីបើកមហាសន្និបាតលើកទី៨ របស់សភាតំបន់អាស៊ី (អេភីអេ)
# "ការជម្រុញសន្តិភាព ការផ្សះផ្សា និងការសន្ទនានៅតំបន់អាស៊ី"
# រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥

3

- *សូមគោរព សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា*
- *សូមគោរព សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា*
- *សូមគោរព ឯកឧត្តម មៀន រ៉ាហ្សា រ៉ាបានី* ***(Mian Raza Rabbani)*** *ប្រធានសភាតំបន់អាស៊ី (អេភីអេ)*
- *សូមគោរព ឯកឧត្តម ម៉ាស៊ូត អ៊ីស្លាមី អគ្គលេខាធិការស្តីទី នៃសភាតំបន់អាស៊ី (អេភីអេ)*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិ ជាទីមេត្រី*

*ក្នុងនាមព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមសម្តែង នូវការស្វាគមន៍យ៉ាងកក់ក្តៅជូនភ្ញៀវកិត្តិយសដ៏ឧត្តុងឧត្តមទាំងអស់ដែលអញ្ជើញចូលរួមពិធីបើកមហាសន្និបាតលើកទី៨ នៃសភាតំបន់អាស៊ី ដ៏មានសារៈសំខាន់នៅពេលនេះ។*

*ក្រោមប្រធានបទ "ការជម្រុញសន្តិភាព ការផ្សះផ្សា និងការសន្ទនានៅតំបន់អាស៊ី" មហាសន្និបាតលើកទី៨ នៃសភាតំបន់អាស៊ីនេះ នឹងគូសបញ្ជាក់អំពីការចូលរួម និងការទទួលខុសត្រូវជាសកលរបស់យើងទាំងអស់គ្នា នៅក្នុងការពង្រឹង ការថែរក្សាសន្តិភាព និងការដោះស្រាយជម្លោះតាមមធ្យោបាយសន្តិវិធីនៅក្នុងតំបន់អាស៊ី ក៏ដូចជាសកលលោកទាំងមូល។ ជម្លោះ ឬអំពើហិង្សា តែងបង្កផលវិបាកជាច្រើនដល់មនុស្សជាតិ។ ជម្លោះតែងតែបង្កវិនាសកម្ម ការបាត់បង់អាយុជីវិត ទុក្ខវេទនា ការព្រាត់ប្រាស់ ការបំផ្លិចបំផ្លាញ និងការបម្លាស់ទីរបស់ប្រជាជនចំណាកស្រុក និងថែមទាំងជាឧបសគ្គដ៏ធំ ដែលធ្វើឲ្យរាំងស្ទះដល់ជំហានទៅមុខ និងការអភិវឌ្ឍលើគ្រប់វិស័យ។*

*ជម្លោះនៅក្នុងប្រទេសមួយ តែងជះឥទ្ធិពលអវិជ្ជមានដល់ប្រទេសជិតខាង និងតំបន់ទាំងមូលផងដែរ។ ជាមួយនេះ សហប្រតិបត្តិការអន្តរវិស័យរវាងប្រទេសតែងត្រូវរាំខាន។ សន្តិភាព ស្ថេរភាព និងសន្តិសុខតំបន់ស្ថិតនៅក្រោមការគំរាមកំហែង។*

*ប្រទេសកម្ពុជា ជាប្រទេសមួយនៅក្នុងទ្វីបអាស៊ីដែលបានឆ្លងកាត់សង្គ្រាមស៊ីវិល និងជម្លោះផ្ទៃក្នុងជាច្រើនទសវត្ស។ ជាពិសេសរបបប្រល័យពូជសាសន៍ខ្មែរក្រហម បានធ្វើឲ្យប្រទេសនេះរងគ្រោះដោយការបំផ្លិចបំផ្លាញដល់កម្រិតសូន្យ។ ក្រោយបរាជ័យនៃរបបខ្មែរក្រហមក្នុងឆ្នាំ១៩៧៩ សង្គ្រាមស៊ីវិលនៅប្រទេសកម្ពុជាមិនទាន់ត្រូវបានបញ្ចប់នៅឡើយទេ។ អន្តរាគមន៍របស់អង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិបានជោគជ័យត្រឹមតែមួយចំណែកប៉ុណ្ណោះនៅក្នុងការស្វែងរកសន្តិភាព និងឯកភាពជាតិពេញលេញជូនកម្ពុជា។ កត្តាផ្ទៃក្នុងជាពិសេសការបង្រួបបង្រួមផ្សះផ្សាជាតិ គឺជាកត្តាគន្លឹះដែលពុំអាចខ្វះបាន។*

*ហេតុផលនេះបានជម្រុញឲ្យកម្ពុជាពុះពារឧបសគ្គជាច្រើនដោយខ្លួនឯងតាមរយៈការបន្តសន្ទនាគ្នា ក្រោមរូបភាព នៃការចរចារដើម្បីផ្សះផ្សាបង្រួបបង្រួមជាតិ។ ជាក់ស្តែងនៅឆ្នាំ១៩៩៨ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញ នូវគោលនយោបាយ* ***"ឈ្នះ-ឈ្នះ"*** *ដើម្បីបញ្ចប់ជម្លោះប្រដាប់អាវុធផ្ទៃក្នុងដែលអូសបន្លាយជាច្រើនទសវត្សមកហើយ។ ការធ្វើសមាហរណកម្មទាហានខ្មែរក្រហមចូលក្នុងសង្គមជាតិបានប្រព្រឹត្តទៅដោយគ្មានការបង្ហូរឈាម។ នេះជាការខិតខំជាអតិបរមាដើម្បីការពារអធិបតេយ្យភាព និងបូរណភាពទឹកដី បញ្ចប់ជម្លោះតាមការបង្រួបបង្រួមផ្សះផ្សាជាតិ និងកសាងសន្តិភាពពេញលេញជូនប្រជាជន និងប្រទេសកម្ពុជា។*

*កត្តាខាងលើនេះ បានបើកនូវទំព័រថ្មីជាប្រវត្តិសាស្ត្ររបស់កម្ពុជា ដែលបច្ចុប្បន្ននេះមានមុខមាត់ថ្មី មានការអភិវឌ្ឍដ៏លឿន និងមានកិត្យានុភាពឡើងវិញក្នុងក្របខណ្ឌតំបន់ និងពិភពលោក។*

*សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី*

*សន្តិភាព គឺជាកត្តាចាំបាច់បំផុតសម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍប្រទេស។ បច្ចុប្បន្នប្រទេសកម្ពុជា មានលទ្ធភាពកសាង និងអភិវឌ្ឍប្រទេសឆាប់រហ័សប្រកបដោយកំណើនសេដ្ឋកិច្ចក្នុងអត្រាជាមធ្យម៧ភាគរយក្នុងមួយឆ្នាំ។ ដោយហេតុថា កម្ពុជាទទួលបានសន្តិភាពបរិបូរណ៍ សន្តិសុខ ឯកភាពជាតិ និងស្ថេរភាពនយោបាយពិតប្រាកដ ប្រជាពលរដ្ឋបានរស់នៅជួបជុំគ្រួសារដោយគ្មានការភ័យខ្លាច មានសិទ្ធិសេរីភាពគ្រប់បែបយ៉ាងដោយគិតទាំងសិទ្ធិធ្វើនយោបាយទៅតាមបំណងប្រាថ្នារបស់ពួកគេផងដែរ។*

*ដោយក្តីស្រឡាញ់សន្តិភាព និងក្នុងនាមជាសមាជិកអង្គការសហប្រជាជាតិ កម្ពុជាបានរួមចំណែកយ៉ាងសកម្មនៅលើឆាកអន្តរជាតិ ក្នុងការរក្សាសន្តិភាព និងសន្តិសុខនៅក្នុងពិភពលោក តាមរយៈការបញ្ជូនកងរក្សាសន្តិភាព និងកងកម្លាំងដោះមីនបំពេញបេសកកម្មនៅប្រទេសមួយចំនួនក្រោមឆ័ត្រអង្គការសហប្រជាជាតិ។ ដើម្បីថែរក្សាសន្តិភាព និងស្ថេរភាពនយោបាយដែលទទួលបានដោយលំបាកនេះ កម្ពុជានឹងបន្តប្រកាន់ខ្ជាប់ នូវការអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងវប្បធម៌ នៃការសន្ទនាដែលជាមូលដ្ឋានគ្រឹះនៃការជម្រុញសន្តិភាព និងការផ្សះផ្សាបង្រួបបង្រួមជាតិ។*

*ការសន្ទនា និងការផ្សះផ្សា គឺជាវិធីសាស្ត្រតែមួយគត់ដើម្បីបញ្ចប់ជម្លោះប្រកបដោយសន្តិវិធី និងឈ្នះ-ឈ្នះទាំងអស់គ្នា។ ក្នុងន័យនេះសភាមានតួនាទីមួយដ៏សំខាន់នៅក្នុងដំណើរការនេះ។*

*ក្រោមដំបូលនៃរដ្ឋធម្មនុញ្ញ សភាគឺជាស្ថាប័នដែលអនុម័ត ឬមិនអនុម័តឲ្យប្រទេសមួយធ្វើសង្គ្រាម។ ក្រៅពីដើរតួនាទីតំណាងឲ្យប្រជាពលរដ្ឋ និងតួនាទីតាមដានត្រួតពិនិត្យលើការអនុវត្តគោលនយោបាយជាតិ និងអន្តរជាតិរបស់រដ្ឋាភិបាល សភាក៏នៅមានតួនាទីមួយទៀត គឺតួនាទីតាក់តែងច្បាប់។ ឥរិយាបថនៃការអនុវត្តតួនាទីនេះ នឹងកំណត់ជោគវាសនារបស់ប្រទេស និងភាពខុសគ្នារវាងសន្តិភាព និងជម្លោះ។ ការតាក់តែងច្បាប់ដែលមានប្រសិទ្ធភាពបង្ការជម្លោះ គឺជាប្រការសំខាន់ណាស់ដែលគួរតែសមាជិកសភា និងគណបក្សនយោបាយទាំងអស់រួបរួមគ្នាប្រកបដោយសុឆន្ទៈដើម្បីសហប្រតិបត្តិការគ្នាស្វែងរកដំណោះស្រាយរួមមួយឲ្យបានសមស្របសម្រាប់ឧត្តមប្រយោជន៍ជាតិ។*

បន្ថែមលើនេះ នយោបាយការទូតសភាដែលជានិន្នាការថ្មី នៃយុគសម័យនេះ ក៏រួមចំណែកក្នុងការជម្រុញសន្តិភាព និងការផ្សះផ្សាជម្លោះទាំងក្នុងតំបន់ និងពិភពលោកប្រកបដោយប្រសិទ្ធភាពផងដែរ។ យន្តការនេះ នឹងបង្កើតឲ្យមានកិច្ចសហប្រតិបត្តិការសភាទាំងកម្រិតនយោបាយ និងបច្ចេកទេសក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី។ អន្តរកម្មរវាងសភា អាចធ្វើឡើងតាមការផ្លាស់ប្តូរទស្សនកិច្ច និងការសន្ទនាគ្នាពាក់ព័ន្ធនឹងវិស័យសន្តិសុខ និងផលប្រយោជន៍រួមសំដៅពង្រឹងមិត្តភាព ស្មេរភាព សន្តិសុខ និងកិច្ចសហប្រតិបត្តិការ។

ដោយឡែក នៅក្នុងបរិបទកម្ពុជា ការប្រែក្លាយប្រព័ន្ធសភាមួយថ្នាក់មកជាប្រព័ន្ធសភាពីរថ្នាក់ដោយការបង្កើតឲ្យមានព្រឹទ្ធសភាឡើងវិញនៅក្នុងឆ្នាំ១៩៩៩ គឺជាប្រព័ន្ធតុល្យភាពមួយដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងពង្រីកការផ្សះផ្សាបង្រួមបង្រួមជាតិ និងនីតិរដ្ឋប្រកបដោយប្រសិទ្ធភាព។ ជាងនេះទៅទៀតប្រព័ន្ធសភាពីរថ្នាក់នៅកម្ពុជាក៏មានគុណសម្បត្តិចំបងដូចជាការពង្រឹងតួនាទីតំណាង និងជួយលើកកម្ពស់គុណភាពតាក់តែងច្បាប់ និងអភិបាលកិច្ចល្អ ជាពិសេសការរួមចំណែកពុំអាចខ្វះបានក្នុងការពង្រឹងពង្រីកលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ម្យ៉ាងទៀត គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ក៏ជាស្នូលនៃសុខដុមនីយកម្មជាតិ និងជាការតភ្ជាប់និរន្តរភាព នៃអំណាចរដ្ឋពីថ្នាក់លើដល់ថ្នាក់ក្រោម និងពីថ្នាក់ក្រោមដល់ថ្នាក់លើវិញដែរ។

ជាទីបញ្ចប់ ខ្ញុំសូមសម្តែងក្តីសង្ឃឹមយ៉ាងមុតមាំថា មហាសន្និបាតលើកទី៨ នៃសភាតំបន់អាស៊ីនេះ នឹងប្រព្រឹត្តទៅដោយជោគជ័យ និងទទួលបានលទ្ធផលជាផ្លែផ្កា ដើម្បីជម្រុញឲ្យសភាស្គាល់កាន់តែច្បាស់អំពីតួនាទីរបស់ខ្លួន នៅក្នុងការរួមចំណែកកសាងសន្តិភាព ការផ្សះផ្សាជម្លោះជាតិ និងអន្តរជាតិ ដើម្បីឈានឆ្ពោះទៅការអភិវឌ្ឍ និងវិបុលភាព។

ខ្ញុំសូមឆ្លៀតឱកាសនេះ ជូនពរសូមឲ្យការស្នាក់អាស្រ័យនៅក្នុងមាតុភូមិអង្គរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវអន្តរជាតិ ប្រកបដោយសុវត្ថិភាព និងភាពសប្បាយរីករាយ។

សូមគោរពជូនពរ សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា ទទួលបានសុខភាពល្អ សុភមង្គល និងជោគជ័យកុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ

*Translation*

**SPEECH**
**By**
Samdech Vibol Sena Pheakdei SAY CHHUM
President of the Senate of the Kingdom of Cambodia
at the opening of the 8th Plenary Session of the Asian Parliamentary Assembly (APA) under the theme
"Promoting Peace, Reconciliation and Dialogue in Asia"
Phnom Penh, 09 December 2015

- Samdech Akka Moha Ponhea Chakrei HENG SAMRIN, President of the National Assembly of the Kingdom of Cambodia
- Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia
- Honorable Mian Raza Rabbani, President of the APA
- H.E Dr. Masoud Islami, Acting Secretary General of APA
- Honorable Colleagues
- Excellencies, Ladies and Gentlemen

On behalf of the Senate of the Kingdom of Cambodia, I would like to extend my warmest welcome to all distinguished guests on the opening of the 8th Plenary Session of Asian Parliamentary Assembly (APA).

Under the theme "Promoting Peace, Reconciliation and Dialogue in Asia", this meeting will emphasis our participation and global responsibility in promoting peace and conflict resolution through peaceful means in Asia and across the world. Conflicts and violence often have negative effects on mankind, loss of lives, suffering, separation, destruction and migration impeding progress and developments in all sectors.

Internal conflicts in one country often have negative impacts on neighboring countries and whole regions. At the same time, multi-sector cooperation between countries is often interrupted. Peace, stability and regional security also come under threat.

Cambodia is a country in Asia that went through civil wars and internal conflicts for decades. The genocidal regime of the Khmer Rouge totally destroyed to this country. After the fall of the Khmer Rouge regime in 1979, civil war in Cambodia did not end yet. Intervention by the United Nations and international communities to bring full peace and unity to Cambodia had only partial success. Internal factors, especially national reconciliation was indispensable factor for bringing peace to the country.

This was what prompted Cambodia to try to overcome obstacles and challenges by itself through continued dialogue under the format of negotiations for the sake of national reconciliation. For instance, in 1998, the Head of the Royal Government introduced "Win-Win" policy to end the internal armed conflicts that had dragged on in Cambodia for decades. Integration of the Khmer Rouge military into society was done without bloodshed. This proved to be one of the biggest efforts in protecting sovereignty and national integrity, ending conflict through national reconciliation and bringing full peace to the country and the Cambodian people.

These factors opened a new chapter for Cambodian history filled with new images of rapid development and regained national prestige under regional and global frameworks.

**Samdech, Honorable Members of Parliaments, Excellencies, Ladies and Gentlemen**

Peace is the most important factor for the survival of the people and national development. At present, Cambodia is able to develop and build the country with an average economic growth of 7 percent annually. Due to the fact that Cambodia has attained full peace, security, national unity and political stability, Cambodian people are now living without fears and enjoying all rights including the right to engage in politics according to their wishes.

Being a peace-loving country and a member of the United Nations, Cambodia has been actively engaging in international security and peace-keeping activities by sending peace keeping forces and demining squads to several countries under the UN umbrella. Therefore, to preserve this hard-earned peace and stability, Cambodia is committed to upholding its multiparty liberal democracy and culture of dialogue which are the basic foundation of promoting peace and national reconciliation.

Dialogue and national reconciliation are the only way to end conflicts peacefully. In this regard, the Parliament has an important role to play in the process.

Under the constitution, Parliament is an institution that approves and rejects a country from going to war. Besides the role of representation and overseeing the implementation of government's national and international policies, Parliament also has another role, the legislative role. The manner in which this role is played will determine the future and destiny of a country. Effective legislation that can prevent conflicts is so crucial that parliamentarians and political parties should be inspired to work together to seek consensus and common goals for greater national interests.

On top of that, Parliamentary Diplomacy is one of the latest trends in this era effectively contributing to promoting peace and reconciliation in the region and across the world. This mechanism promotes both technical and political cooperation in either bilateral or multilateral frameworks. Parliamentary interaction can be done through exchanges of visits and dialogues in area such as security and mutual interest with the aim of strengthening friendship, stability, peace, security and cooperation.

In the Cambodian context, the transformation from a unicameral to bicameral parliament through the establishment of the Cambodian Senate in 1999 was a system of checks-and-balances which significantly and effectively contributed to national reconciliation and strengthening of rule of law. Additionally, the bicameral system in Cambodia also helps to promote representative role, quality of legislation and good governance, particularly in strengthening of democracy at the sub national level. On the other hand, our decentralization and de-concentration policy is a key factor behind national harmonization and a link that ensures movement of power from the central to the local government and vice versa.

Lastly, I deeply hope that this 8$^{th}$ Plenary Session of the Asian Parliamentary Assembly achieves great success and fruitful results so our parliaments are more aware of their roles in contributing to peace building as well as national and international reconciliation for the sake of development and prosperity.

I would like to take this opportunity to wish our international delegates and guests a safe and pleasant stay in the Kingdom of Angkor.

I would also like to wish Samdech, Honorable Colleagues, Excellencies, Ladies and Gentlemen the best of health, happiness and success.

Thank you